**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## វិធានការឆ្លើយតប ការការពារ និងការត្រៀមអន្តរាគមន៍លើការចម្លងជំងឺកូវីដ ១៩ (COVID-19) និងជំងឺឆ្លងផ្សេងៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា មកដល់ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០នេះ ពុំមានប្រជាជនកម្ពុជាណាម្នាក់ ត្រូវបានរកឃើញថាមានជំងឺកូវីដ១៩ (COVID-19) នោះទេ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជាបានធ្វើតេស្តសំណាកបុគ្គលដែលសង្ស័យសរុបចំនួន១៣៥នាក់ គិតមកត្រឹមថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ តែមិនមានរកឃើញអ្នកណាម្នាក់នៅក្នុងប្រទេសកម្ពុជាមានវីរុសកូវីដ១៩ នោះឡើយ។ កន្លងមក មានតែមួយករណីគត់ដែលបានរកឃើញលើបុរសជនជាតិចិន នៅខេត្តព្រះសីហនុនាថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ ហើយបុរសរូបនេះបានជាសះស្បើយ និងបានវិលត្រឡប់ទៅប្រទេសកំណើតវិញហើយដែរ ក្រោយពីក្រសួងបានអនុញ្ញាតឲ្យចាកចេញពីមន្ទីរពេទ្យនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០។ម្យ៉ាងទៀត ក្រសួងសុខាភិបាលបានចូលរួមធ្វើប្រតិបត្តិការយ៉ាងសកម្មក្នុងការជួយដល់អ្នកដំណើរ និងអ្នកបម្រើការនាវាទេសចរណ៍ MS Westerdam ដោយជោគជ័យ ហើយក្រសួងបានចេញសេចក្តីប្រកាសព័ត៌មានរួចហើយដែរនូវលទ្ធផលនៃការពិនិត្យ និងធ្វើតេស្តសំណាកមនុស្សលើនាវានេះ បានចំនួនសរុប ១.៥៨០នាក់ ដែលមិនមានអ្នកណាម្នាក់ត្រូវបានរកឃើញថាមានវីរុសកូវីដ១៩ នោះឡើយ ហើយបើគិតពីថ្ងៃដែលនាវាបានចាកចេញពីហុងកុង មកទល់ពេលនេះ មានរយៈពេល ៣១ថ្ងៃ និងបើគិតពីថ្ងៃដែលអ្នកដំណើរចុះចេញពីនាវានៅកំពង់ផែក្រុងព្រះសីហនុ មកដល់ពេលនេះ គឺមានរយៈពេល ១៨ថ្ងៃ ហើយដែរ។ ជាការសន្និដ្ឋានរួមចុងក្រោយ គឺមនុស្សនៅលើនាវា MS Westerdam ទាំងអស់ (ដែលមាន ៤១ សញ្ជាតិ) មិនមានអ្នកណាម្នាក់មានវីរុសកូវីដ១៩ នោះឡើយ ហើយពួកគេបានទៅដល់ផ្ទះសម្បែងនៅតាមប្រទេសរបស់ពួកគេរៀងៗខ្លួន ហើយក៏មិនមានការរាយការណ៍ណាមួយថា មានអ្នកណាម្នាក់មានបញ្ហាសុខភាពពាក់ព័ន្ធទៅនឹងវីរុសកូវីដ១៩ នេះដែរ។

ចាប់តាំងពីមានការប្រកាសករណីវិជ្ជមានវីរុសកូវីដ១៩ ជាលើកដំបូងនៅទីក្រុងវូហាន ខេត្តហ៊ូប៉េ (Hubei) នៃសាធារណរដ្ឋប្រជាមានិតចិន ដោយមិនបង្អែបង្អង់ និងការយកចិត្តទុកដាក់ខ្ពស់លើសុខភាពប្រជាជនកម្ពុជាទូទៅ ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានចាត់ចែងជាបន្ទាន់នូវការដាក់ម៉ាស៊ីនស្កេនកំដៅនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ អាកាសយានដ្ឋានអន្តរជាតិសៀមរាប និងអាកាសយានដ្ឋានខេត្តព្រះសីហនុ ហើយក៏បានពង្រាយក្រុមការងារចត្តាឡីស័ក ឲ្យនៅប្រចាំការនៅតាមទីតាំងទាំងនេះផងដែរ ព្រមទាំងបានត្រៀមលក្ខណៈជាបន្តបន្ទាប់ ដែលឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រី សូមជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា ចាប់តាំងពីថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ ក្រសួងសុខាភិបាលបានអនុវត្តនូវវិធានការចាំបាច់ៗ ស្របតាមគោលការណ៍ណែនាំស្តង់ដារប្រតិបត្តិ និងច្បាប់និយ័តកម្មអន្តរជាតិឆ្នាំ២០០៥ (IHR 2005) របស់អង្គការសុខភាពពិភពលោក ព្រមទាំងបាន និងកំពុងបង្កើន ពង្រឹងសកម្មភាពនៅទូទាំងប្រទេស មានដូចខាងក្រោម៖

១. ពង្រឹងប្រព័ន្ធតាមដានដែលមានស្រាប់នៅតាមគ្រប់មន្ទីរពេទ្យ និងមណ្ឌលសុខភាព លើជំងឺរលាកសួតស្រួចស្រាវ ជំងឺរលាកសួតធ្ងន់ធ្ងរ ជំងឺគ្រុនក្ដៅ និងជំងឺផ្ដាសាយ។

២. ក្រសួងបានពង្រាយរួចហើយនូវក្រុមឆ្លើយតបបន្ទាន់ (Rapid Response Team or RRT) ប្រហែលជា ២.០០០នាក់ ដែលទទួលបានការបណ្ដុះបណ្ដាលរួចហើយ ដែលមាននៅគ្រប់រាជធានី-ខេត្ត ទាំង២៥ ក្នុងការតាមដាន និងឆ្លើយតបជំងឺកើតឡើងថ្មីៗ ត្រៀមលក្ខណៈឆ្លើយតបភ្លាមៗក្នុងករណីបើមានការចម្លងជំងឺកូវីដ១៩ ឬជំងឺឆ្លងណាមួយ ដែលអាចកើតមានឡើងនៅក្នុងប្រទេសជាយថាហេតុ។

៣. ពង្រឹងប្រព័ន្ធតាមដាន និងរាយការណ៍ទាន់ហេតុការណ៍ 115 (អត់មានថវិកាក្នុងទូរស័ព្ទលោកអ្នក ក៏អាចហៅចូលបានដែរ) ដោយប្រចាំការ២៤ម៉ោង ក្នុង១ថ្ងៃ ៧ថ្ងៃ ក្នុង១សប្ដាហ៍ ដែលជាប្រព័ន្ធឌីជីថល បាញ់ទៅទូរស័ព្ទដៃគ្រូពេទ្យ១០នាក់ ចាំទទួលព័ត៌មានពីសាធារណជនគ្រប់ប្រភេទ ពីគ្រូពេទ្យដែលរាយការណ៍ពីមន្ទីរពេទ្យរដ្ឋ និងឯកជន ពីមន្ទីរពិសោធន៍នានា ពីអ្នកដំណើរបរទេស រួមមាន ចិន អាមេរិក ថៃ ជាដើម និងពីអ្នកសារព័ត៌មាន និងពីគ្រប់បុគ្គល មិនប្រកាន់សញ្ជាតិ វណ្ណៈ និងនិន្នាការនយោបាយ ដែលមានការសង្ស័យ និងមានចម្ងល់លើបញ្ហាសុខភាពរបស់ពួកគេ។

៤. តាមដានដោយយកចិត្តទុកដាក់ ដើម្បីចាប់បានករណីសង្ស័យជំងឺកូវីដ១៩ ដោយដាក់ម៉ាស៊ីនស្កេនកំដៅ និងប្រើឧបករណ៍ដៃស្ទង់កំដៅ (ម៉ាស៊ីនបាញ់ស្ទង់កំដៅដោយដៃ) នៅគ្រប់ច្រកចេញ-ចូល អន្តរជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទាំងផ្លូវអាកាស ផ្លូវទឹក និងផ្លូវគោក ដោយក្រុមឆ្លើយតបបន្ទាន់ និងក្រុមចត្តាឡីស័ករបស់ក្រសួង និងរបស់មន្ទីរសុខាភិបាលរាជធានី-ខេត្ត ដែលពាក់ព័ន្ធ។

៥. បានត្រៀមបន្ទប់ដាក់អ្នកជំងឺឲ្យនៅដាច់ដោយឡែកនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត សម្រាប់រាជធានីភ្នំពេញ និងនៅមន្ទីរពេទ្យខេត្តនៅតាមបណ្ដាខេត្តទាំងអស់នៅក្នុងប្រទេស។

៦. បានត្រៀម និងបានចែកចាយ សម្ភារៈការពារខ្លួន សម្ភារៈសម្រាប់មន្ទីរពិសោធន៍ បរិក្ខារពេទ្យ និងបានត្រៀមឱសថចាំបាច់ៗ សម្រាប់ការព្យាបាល ក្នុងករណីសង្ស័យ ឬករណីដែលរកឃើញមានវីរុសកូវីដ១៩។ ក្រសួងក៏កំពុងតែរៀបចំទិញរថយន្តគិលានសង្គ្រោះបន្ថែមទៀត ដើម្បីបម្រើសុខភាពជូនបងប្អូនប្រជាពលរដ្ឋ ក្នុងករណីចាំបាច់។

៧. ក្រសួងសុខាភិបាលបានត្រៀមរៀបចំមន្ទីរពិសោធន៍បង្អែកជាតិនៃវិទ្យាស្ថានជាតិសុខភាពសាធារណៈបន្ថែមលើវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដើម្បីស្រាវជ្រាវ និងធ្វើតេស្តរកវីរុសកូវីដ១៩ (COVID-19) សម្រាប់ធ្វើវិភាគសំណាកដែលយកពីករណីសង្ស័យ ដោយផ្អែកលើនិយមន័យ និងភាពចាំបាច់។

៨. បានអភិវឌ្ឍ និងផលិតសម្ភារៈអប់រំសុខភាព មាន៣ភាសាគឺ ខ្មែរ អង់គ្លេស និងភាសាចិន សម្រាប់ផ្សព្វផ្សាយជាសាធារណៈទូទៅ នៅថ្នាក់កណ្ដាល និងថ្នាក់ក្រោមជាតិ នៅតាមមន្ទីរពេទ្យ នៅតាមច្រកចេញ-ចូលអន្តរជាតិ ក្នុងគោលបំណងអប់រំសុខភាពជូនដល់បងប្អូនប្រជាពលរដ្ឋ អំពីវិធានការបង្ការជំងឺឆ្លងកូវីដ១៩ និងបានផ្សព្វផ្សាយជូនដំណឹងណែនាំដល់អាជ្ញាធរពាក់ព័ន្ធទាំងអស់ រួមទាំងអាជ្ញាធរថ្នាក់ក្រោមជាតិ ដល់មន្ទីរពេទ្យជាតិ និងមន្ទីរសុខាភិបាលទាំង២៥ រាជធានី-ខេត្ត ឲ្យធ្វើការអប់រំបង្ការការចម្លងជំងឺកូវីដ១៩ (COVID-19) នៅតាមសហគមន៍ និសាលារៀន ព្រមទាំងការត្រៀមលក្ខណៈជាស្រេច ក្នុងការឆ្លើយតប និងផ្ដល់អន្តរាគមន៍ជាបន្ទាន់ប្រសិនបើមានករណីសង្ស័យ ឬការចម្លងជំងឺណាមួយកើតមានឡើងជាយថាហេតុ។

៩. បានរៀបចំឲ្យមានការបំពេញទម្រង់ប្រកាសសុខភាពអ្នកដំណើរមុនយន្តហោះចុះចតនៅតាមអាកាសយានដ្ឋានអន្តរជាតិនានា ដោយសហការជាមួយអាជ្ញាធរអាកាសចរស៊ីវិល។

១០. ធ្វើបច្ចុប្បន្នភាពស្ថានភាពជំងឺកូវីដ១៩ និងជំងឺឆ្លងផ្សេងៗទៀត ធ្វើសេចក្តីប្រកាសព័ត៌មាន ធ្វើសន្និសីទសារព័ត៌មាន ធ្វើការឆ្លើយតបយ៉ាងសកម្មជាមួយអ្នកសារព័ត៌មាននានា ធ្វើការឆ្លើយតបទៅនឹងព័ត៌មានប្រឌិតបំពុលសង្គម និងផលិត និងផ្តល់ជូននូវសារអប់រំសម្រាប់បង្ការការចម្លងជំងឺកូវីដ១៩ និងជំងឺឆ្លងផ្សេងៗទៀតជាប់ជាប្រចាំតាមរយៈទំព័រហ្វេសប៊ុកដែលមានឈ្មោះថា ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទំព័រហ្វេសប៊ុកនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង និងគេហទំព័ររបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសំភារៈអប់រំសុខភាព ដែលអាចទាញយកមកប្រើប្រាស់បាន។ ក្រសួងបានធ្វើ និងបន្តធ្វើបទសម្ភាសន៍នានា និងធ្វើសន្និសីទសារព័ត៌មានជាបន្តបន្ទាប់ទៀត ដើម្បីផ្តល់ជាសារអប់រំសុខភាពនិងការពារការចម្លងជំងឺ និងជំរុញការចូលរួមពីប្រជាជន និងបុគ្គលគ្រប់រូប ចូលរួមអនុវត្តនវិធានការការពារពីការចម្លងជំងឺកូវីដ១៩ និងជំងឺឆ្លងផ្សេងៗទៀត ដែលមានដូចខាងក្រោម។

១១. បាន និងបន្តសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីផ្តន្ទាទោសតាមច្បាប់ លើជនដែលបានប្រឌិតព័ត៌មានបំពុលសង្គម ដែលមិនមែនជាការពិត។ ក្រសួងសុខាភិបាល សូមអំពាវនាវហើយ អំពាវនាវទៀត សូមបងប្អូនប្រជាពលរដ្ឋ កុំជឿតាមព័ត៌មានប្រឌិតទាំងនោះ ដែលគ្មានការពិត រំលោភសិទ្ធិអ្នកដទៃ មាននិន្នាការនយោបាយបោកប្រាស់បង្ខោះរូបបុគ្គលមួយឬច្រើន ដែលខ្វះសីលធម៌ និងក្រមសីលធម៌វិជ្ជាជីវៈ ដែលមិនមានការអនុញ្ញាតពីសាមីជនដែលមានហេតុការណ៍សុខភាពទាំងនោះ ធ្វើឲ្យប៉ះពាល់ដល់កិត្តិយសបុគ្គលទាំងនោះផង ប៉ះពាល់កិត្តិយសប្រទេសផង និងសេចក្តីថ្លៃថ្នូរសង្គមជាតិផង។

១២. ក្រសួងបានបង្កើតក្រុមការងារឆ្លើយតបការចម្លងវីរុសកូវីដ១៩ ដែលដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាលផ្ទាល់ និងមានសមាជិកមកពីផ្នែកពាក់ព័ន្ធ ពីមន្ទីរសុខាភិបាលរាជធានី-ខេត្តទាំង២៥ និងមានទីប្រឹក្សាមកពីអង្គការសុខភាពពិភពលោក (WHO) មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក (US-CDC) វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា (IPC) លោកជំទាវ ពេទ្យ ចន្ទមុនី ហ៊ិន ម៉ាណែត សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងមន្ទីរពេទ្យគន្ធបុប្ផា ដើម្បីរៀបចំធ្វើផែនការ សម្របសម្រួល ដឹកនាំ ចាត់ចែង ឆ្លើយតប និងចាត់វិធានការការពារការចម្លងជំងឺកូវីដ១៩ នេះ។

១៣. បាន និងបន្តធ្វើការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល ក្រុមគ្រូពេទ្យ ផ្នែកពាក់ព័ន្ធនានា និងអ្នកសារព័ត៌មាន ដើម្បីបង្កើនចំណេះដឹង និងចូលរួមការពារការចម្លងវីរុសកូវីដ១៩ ទាំងអស់គ្នា ព្រមទាំងធ្វើការផ្សព្វផ្សាយវិធានការការពារ និងព័ត៌មានពាក់ព័ន្ធទៅនឹងជំងឺកូវីដ១៩ នេះ ដោយប្រើប្រាស់ព័ត៌មានពិតត្រឹមត្រូវ។

១៤. ក្រសួងសុខាភិបាល តាមរយៈសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល កំពុងធ្វើការសិក្សាស្រាវជ្រាវបទពិសោធន៍ ពីសាធារណរដ្ឋប្រជាមានិតចិន និងបណ្តាប្រទេសផ្សេងៗលើសាកលលោកលើជំងឺកូវីដ១៩ សម្រាប់ជាទុនបន្ថែមទៀតក្នុងការត្រៀមនិងប្រតិបត្តិការឆ្លើយតប ការពារ ពិនិត្យ និងព្យាបាលជំងឺកូវីដ១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ដើម្បីបន្តការពារទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅប្រទេសកម្ពុជា **ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល សូមប្រកាសបន្តច្រើនលើកហើយលើកទៀត និងអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ រួមទាំងអ្នកធ្វើដំណើរដែលមានគម្រោងទៅកាន់ ឬត្រឡប់មកពីប្រទេសក្រៅ ជាពិសេសទៅតំបន់ដែលកំពុងកើតជំងឺកូវីដ១៩ (COVID-19) ត្រូវមានការប្រុងប្រយ័ត្នខ្ពស់បំផុត "*ប្រសិនបើលោកអ្នក មានរោគសញ្ញាណាមួយដូចជា*

*គ្រុនក្តៅ ក្អក ពិបាកដកដង្ហើម ទាំងមុន ឬក្នុងអំឡុងពេលធ្វើដំណើរ ឬបន្ទាប់ពីការវិលត្រឡប់មកពីកន្លែងដែលបាន និងកំពុងរាតត្បាតនៅប្រទេសមួយចំនួន ឬបានប៉ះពាល់ជាមួយអ្នកជំងឺកូវីដ១៩ (COVID-19) ដែលអះអាងពីមន្ទីរពិសោធន៍ សូមទាក់ទងទូរស័ព្ទទាន់ហេតុការណ៍ ១១៥ ជាបន្ទាន់។*

ជាមួយគ្នានោះដែរ សូមបងប្អូនប្រជាពលរដ្ឋអនុវត្តនូវវិធានការសាមញ្ញៗមានដូចខាងក្រោមនេះ៖

- ត្រូវលាងដៃឲ្យបានញឹកញាប់ជាមួយសាប៊ូ និងទឹកស្អាត ឬអាល់កុលលាងដៃ បន្ទាប់ពីការប៉ះពាល់ដោយផ្ទាល់ជាមួយអ្នកជំងឺ ឬបរិស្ថានជុំវិញគាត់ ឬនៅពេលឃើញដៃកខ្វក់ ឬប្រឡាក់ មុនពេល និងក្រោយពីការប៉ះពាល់សត្វ ឬវត្ថុផ្សេងៗដែលអាចជាប្រភពមេរោគ
- ពិសារអាហារដែលចម្អិនឆ្អិនល្អ ជាពិសេសសាច់ និងស៊ុត
- ត្រូវខ្ទប់មាត់ និងច្រមុះនៅពេលក្អក ឬកណ្តាស់ ដោយប្រើម៉ាស់ កន្សែង ក្រមា ក្រដាសជូតមាត់ ឬដោយកែងដៃ
- រក្សាចម្ងាយច្រើនជាង១ម៉ែត្រ ពីបុគ្គលដែលមានរោគសញ្ញាផ្លូវដង្ហើមស្រួចស្រាវ
- កាត់បន្ថយជាអតិបរមានូវការយកដៃ មកប៉ះពាល់ភ្នែក ច្រមុះ និងមាត់
- ជៀសវាងការខាកស្តោះនៅទីសាធារណៈ
- ជៀសវាងប៉ះពាល់ជិតស្និទ្ធជាមួយអ្នកមានជំងឺផ្លូវដង្ហើម ដូចជា គ្រុនក្តៅ ក្អក និងកណ្តាស់ ឬផ្តាសាយ ត្រូវនៅឆ្ងាយពីអ្នកក្អក និងកណ្តាស ឲ្យបានលើសពី ១ម៉ែត្រកន្លះ ឡើងទៅ ដើម្បីចៀសវាងការប៉ះពាល់នឹងដំណក់ទឹកមាត់ចេញពីអ្នកដែលក្អក កណ្តាស់ ដែលអាចមានការចម្លងវីរុសកូវីដ១៩ ឬវីរុស ឬមេរោគផ្សេងៗ
- ជៀសវាងប៉ះពាល់ជិតស្និទ្ធ កសិដ្ឋានដែលមានសត្វរស់ ឬសត្វព្រៃ ឬកន្លែងដែលគេដឹងថាមានវីរុសកំពុងចរាចរ
- បុគ្គលិកសុខាភិបាលដែលផ្តល់ការថែទាំអ្នកជំងឺត្រូវប្រកាន់ខ្ជាប់នូវវិធានការបង្ការការចម្លងរោគក្នុងគ្រឹះស្ថានសុខាភិបាលឲ្យបានហ្មត់ចត់ និងត្រឹមត្រូវដើម្បីជៀសវាងការឆ្លងជំងឺនេះមកបុគ្គលខ្លួនឯង។

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងការគោរពដ៏ខ្ពង់ខ្ពស់បំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែល **សម្តេចតេជោ** បានគាំទ្រចង្អុលបង្ហាញ លើកទឹកចិត្ត សម្រាប់ប្រតិបត្តិការសុខាភិបាលរហូតទទួលបានជោគជ័យ ដែលជាការសម្រេចចិត្តដ៏មហិមាដ៏ត្រឹមត្រូវបំផុត ពោរពេញដោយសន្តានចិត្តមនុស្សធម៌ គោរពសិទ្ធិ និងការរស់រានមានជីវិតរបស់មនុស្សលោក ក្នុងការអនុញ្ញាតឲ្យនាវាខ្នាតយក្ស Holland-America Line MS Westerdam ផ្ទុកដោយអ្នកដំណើរសរុប ១.៤៥៥នាក់ និងអ្នកបម្រើការសរុបចំនួន ៨០២នាក់ ដែលមាន ៤១សញ្ជាតិ (សរុបរួម៖ ២.២៥៧ នាក់) ក្រោយពីមិនមានការអនុញ្ញាតឲ្យចូលចតពីបណ្តាប្រទេសជាច្រើន ហើយជិតអស់ស្បៀង ជិតអស់ប្រេងសម្រាប់នាវា និងកង្វះខាតនូវតម្រូវការផ្សេងៗរបស់មនុស្សទាំងអស់នៅលើនាវានេះ។

ក្រសួងសុខាភិបាល ក៏សូមថ្លែងអំណរគុណជាអនេកចំពោះការគាំទ្រយកចិត្តទុកដាក់ជួយសម្របសម្រួលលើការដឹកជញ្ជូនសំណាកសម្រាប់យកមកធ្វើវិភាគនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា តាមឧទ្ធម្ភាគចក្រ (Helicopter) ពីសំណាក់ ឯកឧត្តមឧត្តមសេនីយឯក ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជា

ការកងទ័ពជើងគោក ព្រមទាំងក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដី សមត្ថកិច្ចពាក់ព័ន្ធទាំងអស់នៅក្នុងប្រតិបត្តិការសុខាភិបាលសម្រាប់នាវា MS Westerdam នេះ។

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល ក៏សូមថ្លែងនូវការកោតសរសើរ ចំពោះការប្តេជ្ញាចិត្ត និងឆន្ទៈមុះមុតរបស់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល ក្រុមគ្រូពេទ្យទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានធ្វើសកម្មភាពយ៉ាងសកម្មលើប្រតិបត្តិការសុខាភិបាលកន្លងមកនេះ ដែលជាការទទួលខុសត្រូវ និងរួមចំណែកប្រកបដោយឆន្ទៈមនុស្សធម៌ពិតប្រាកដ មិនរើសអើងពូជសាសន៍ និងអនុវត្តតាមក្រមសីលធម៌ គោលការណ៍ការប្រតិបត្តិស្តង់ដារ ព្រមទាំងច្បាប់និយ័តកម្មសុខភាពអន្តរជាតិឆ្នាំ២០០៥ (IHR 2005) របស់អង្គការសុខភាពពិភពលោក ដោយមានការចូលរួមសហការសម្របសម្រួលក្នុងការប្រតិបត្តិការពីអង្គការសុខភាពពិភពលោក (WHO) មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក (US-CDC) វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា (Institute Pasteur du Cambodge) និងបណ្តាតំណាងស្ថានទូតពាក់ព័ន្ធ។

សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងក្រសួងសុខាភិបាល៖

- លេខទូរស័ព្ទទាន់ហេតុការណ៍ដោយឥតគិតថ្លៃ 115 ទោះគ្មានថវិកាក្នុងទូរស័ព្ទរបស់អ្នកក៏អាចទូរស័ព្ទចូលបានដែរ ឬទំនាក់ទំនងលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨។

ថ្ងៃចន្ទ ៩កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០